RÉPUBLIQUE FRANÇAISE
*Liberté*
*Égalité*
*Fraternité*

INSTITUT FRANÇAIS

*Liberté*
*Créativité*
*Diversité*

# សំណើច



ពីថ្ងៃទី 08.02
ដល់ថ្ងៃទី 11.04

ពិព័រណ៍

# ផ្ទុះសំណើច!”

## វិទ្យាស្ថានបារាំងនៅកម្ពុជា



Marie Losier, *Papal BrokenDance*, 2008, 16mm
© Galerie Anne Barrault

# រដូវកាលវប្បធម៌ *"ផ្ទុះសំណើច!"* ចាប់ពីថ្ងៃទី ៨ ខែកុម្ភៈ ដល់ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០២៤

រដូវកាលវប្បធម៌នេះ ឧទ្ទិសដល់ការកំប្លែងលេងសើច និងរឿងកំប្លែងបែបសម្តែង "ផ្ទុះសំណើច!" គឺធ្វើឡើងក្នុងក្របខណ្ឌខែនៃទិវាអន្តរជាតិហ្វ្រង់កូហ្វូនី។ យើងសូមគោរពអញ្ជើញលោកអ្នកចូលរួមដំណើរកម្សាន្តបែបកំណាព្យកាបឃ្លោង និងកំប្លែងលេងសើច ដែលរឿងកំប្លែង ភាពទន់ភ្លន់មិនច្បាស់លាស់ ការកំប្លែងលេងសើចនិងភាពសប្បាយរីករាយនឹងត្រូវលើកមកជាកិត្តិយស្តដូច្នេះហើយនឹងផ្តល់ជូននូវពេលវេលាដ៏ស្រស់ស្រាយរីករាយ និងកំប្លែង ដើម្បីស្វែងយល់អំពីពិភពលោកសហសម័យ នៅវិទ្យាស្ថានបារាំងកម្ពុជា។

ហ្វ្រង់កូហ្វូនី នឹងដើរតួនាទីចម្បងនៅក្នុងរដូវកាលវប្បធម៌ "ផ្ទុះសំណើច!" នេះដើម្បីអបអរសាទរសហគមន៍អ្នកនិយាយភាសាបារាំង ដែលមានវាគ្មិនជាង ៣២១ លាននាក់នៅទូទាំងពិភពលោក។ កិច្ចប្រជុំកំពូល ហ្វ្រង់កូហ្វូនី លើកក្រោយនឹងធ្វើឡើង នៅទីក្រុងអន្តរជាតិថ្មីនៃភាសាបារាំង ទីក្រុង Villers-Cotterêts នៅប្រទេសបារាំង។

រដូវកាលវប្បធម៌នេះនៅវិទ្យាស្ថានបារាំងនៃកម្ពុជា មានគោលបំណង លើកកម្ពស់និងធ្វើឱ្យស៊ីជម្រៅចំណេះដឹងនៃភាសាបារាំង នៃហ្វ្រង់កូហ្វូនី ក៏ដូចជាឱកាសវប្បធម៌ និងសេដ្ឋកិច្ចនៅក្នុងលំហនេះដែរ។ រដូវកាលវប្បធម៌នេះប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ការបង្រៀន និងការប្រើប្រាស់ភាសាបារាំងគាំទ្រដល់ការអភិវឌ្ឍឧបករណ៍ឌីជីថលជាភាសាបារាំងពង្រឹងទំនាក់ទំនងរវាងការអប់រំ និងទស្សនៈវិស័យវិជ្ជាជីវៈ ទន្ទឹមគ្នានោះដែរនឹងលើកកម្ពស់សិទ្ធិស្ត្រីនិងចល័តភាពរបស់យុវជន។

យើងសូមគោរពអញ្ជើញលោកអ្នកយ៉ាងកក់ក្តៅឱ្យមកចូលរួមអបអរទិវាហ្វ្រង់កូហ្វូនីនៅវិទ្យាស្ថានបារាំងនៅព្រឹត្តិការណ៍ជាបន្តបន្ទាប់ជាច្រើននឹងជាចង្វាក់កន្ត្រាក់អារម្មណ៍នៅក្នុងរដូវកាលវប្បធម៌នេះដោយចាប់ផ្តើមជាមួយនឹងការពិព័រណ៍មួយបែបសិក្ខាលម្អិតរបស់សិល្បការិនីជនជាតិបារាំងលោកស្រីម៉ារី ឡូស៊ីយ៉េ (Marie Losier) ។

ការតាំងពិព័រណ៍នេះ នឹងនាំលោកអ្នកឆ្ពោះទៅកាន់ដំណើរផ្សងព្រេងមួយ បែបកំណាព្យកាបឃ្លោង និងកំប្លែងលេងសើចនៅវិចិត្រសាលនៃវិទ្យាស្ថានបារាំង ដោយស្វែងយល់អំពីជីវិតតាមរយៈក្រសែរភ្នែកដ៏ពិសេសរបស់សិល្បៈការិនី។ដោយសារដំណើរការប្រមូលផ្តុំដ៏ប៉ិនប្រសប់ លោកស្រីបានរួមផ្សំបញ្ចូលគ្នានូវស្ថានភាពទាំងឡាយ ដែលជួនកាលមិនស៊ីសង្វាក់គ្នាជួនកាលហួសហេតុដោយផ្តល់នូវបទពិសោធន៍ដ៏រស់រវើកនិងដូចសុបិន ដែលការកំប្លែងលេងសើច និងកំណាព្យរួមបញ្ចូលគ្នា។

ល្ខោននិងការសម្តែងឥតព្រៀងទុកនឹងដើរតួនាទីចម្បងនៅក្នុងព្រឹត្តិការណ៍នេះ ដោយមានការចូលរួមសម្តែង ពីក្រុមសិល្បៈនៃអង្គការសកម្មភាពសិល្បៈខ្មែរ (Khmer Art Action ) និងក្រុមសិល្បៈនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងល្ខោនសម្តែងរឿង « L´Avare » របស់ Molière ព្រមទាំងល្ខោនកំប្លែងខ្មែរដែលមានចំណងជើងរងជាភាសាបារាំងនិងភាសាអង់គ្លេស។លោកអ្នកក៏នឹងរីករាយទាក់ទាញអារម្មណ៍ដោយការសម្តែងរបស់ក្រុម Voix au Chapitre, Impro Hok។

ឆាកសម្តែងក៏នឹងត្រូវដឹកនាំដោយក្រុមល្ខោនហ្វ្រង់កូហ្វូនខេត្តសៀមរាប ដែលនឹងធ្វើការសម្តែងបង្ហាញ រឿង "An Investigation in Kent" ដែលដឹកនាំដោយ អ្នកនាង Rejane Lefoul។

ព្រឹត្តិការណ៍នេះនឹងបង្ហាញពីវប្បធម៌បែបស្រលាញ់ចូលចិត្តជាមួយនឹងការប្រកួតប្រជែងបទចម្រៀងជាភាសាបារាំងនិងការធ្វើជាម្ចាស់ផ្ទះនៃពានរង្វាន់ “Ambassadeurs en Herbes” ក៏ដូចជា “La Nuit des idées” ដោយសហការក្នុងភាពជាដៃគូជាមួយវិទ្យាល័យរីណេដេកាត។

វគ្គភាពយន្តមួយ ដែលឧទ្ទិសដល់ទិវាហ្វ្រង់កូហ្វូនី ក៏ដូចជាការផ្តល់សិទ្ធជ្រើសរើសដល់លោកស្រីម៉ារី ឡូស៊ីយ៉េ (Marie Losier )អតីតអ្នករៀបចំកម្មវិធីនៃរោងភាពយន្តវិទ្យាស្ថានបារាំងទីក្រុងញូវយ៉កនឹងមកធ្វើអោយកម្មវិធីនេះកាន់តែកន្ត្រាក់អារម្មណ៍ទៅទៀត។

ពេលវាលាដ៏សំខាន់នៃការផ្តល់សិទ្ធជ្រើសរើសនេះ គឺខ្សែភាពយន្តរបស់លោកស្រី Marie Losier ដែលឧទ្ទិសដល់ការបង្ហាញពិពណ៌នាបែបភាពយន្ត នៃ *" Cassandro, the Exotico!"* - ជារឿងសោកនាដកម្មមួយ ដែលរៀបរាប់ពីប្រវត្តិរបស់អ្នកតស៊ូខ្មើយ ជាអ្នកចំបាប់សេរី ជនជាតិម៉ិកស៊ិកម្នាក់។ ខ្សែភាពយន្តនេះត្រូវតែមើលនិងមើលឡើងវិញក្នុងអំឡុងពេលវគ្គភាពយន្តរបស់យើងដែលផ្តល់សិទ្ធជ្រើសរើសដល់លោកស្រី ម៉ារី ឡូស៊ីយ៉េ ។

លោក វ៉ាឡង់តាំង រ៉ូឌ្រីហ្គេស


© Marie Losier

ផ្ទះសំណើច!

វាចារបស់សិល្បការិនី

ស្នាដៃសម្រាប់ការតាំងពិព័រណ៍ "ផ្ទះសំណើច!"

*If you like it don’t watch it*

*Eat my makeup !*

*Bodhi in my Body*

*Mouth Me !*

ភាពយន្ត-កំប្លែង

*Excesso Chamalo*

*Merry Go round*

ប្រអប់ភាពយន្ត

រូបភាពបញ្ឈរ

ការជ្រើសរើសដោយសេរី នៅរោងកុន IFC ដោយ Marie Losier

## « ផ្ទះសំណើច ! »

រដូវកាលវប្បធម៌នេះដែលឧទ្ទិសដល់ការកំប្លែងលេងសើចនិងរឿងកំប្លែងបែបសម្តែង គឺធ្វើឡើងក្នុងខែនៃទិវាអន្តរជាតិហ្វ្រង់កូហ្វូនី។ យើងសូមផ្តល់ជូននូវដំណើរកម្សាន្តមួយបែបកំណាព្យកាបឃ្លោង និងកំប្លែងលេងសើច ដោយផ្តល់ឆាកសម្តែងដល់រឿងកំប្លែង ភាពទន់ភ្លន់មិនច្បាស់លាស់ ការកំប្លែងលេងសើច និងភាពសប្បាយរីករាយ ដើម្បីក្រេបយកពិសោធន៍ និងពេលវេលាដ៏រីករាយនិងកំប្លែងដើម្បីរីករាយជាមួយពិភពលោកនៅថ្ងៃនេះនៅវិទ្យាស្ថានបារាំង។ យើងរីករាយក្នុងការចូលទៅក្នុងពិភពសុបិននៃស្នាដៃរបស់ លោកស្រី Marie Losier ដែលសិល្បការិនីកូនកាត់ ដោយដាក់បញ្ចូលគ្នានូវរូបភាពតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជាគំនូរ ការសម្តែង រូបភាពបម្លាស់ទី និងភាពយន្ត។

លោកស្រី ម៉ារី ឡូស៊ីយ៉េ សូមគោរពអញ្ជើញលោកអ្នក ឱ្យចូលរួមក្នុងការស្វែងរុករកដ៏គួរឱ្យទាក់ទាញមួយ ស្វែងយល់ពីជីវិត តាមរយៈក្រសែភ្នែករបស់លោកស្រី នេះគឺដោយសារដំណើរការប្រមូលផ្តុំ ដែលចាប់យករូបភាពនានា ជួនកាលមិនស៊ីសង្វាក់គ្នា ជួនកាលគួរឱ្យហួសចិត្ត។

លោកស្រីបានដាក់ផ្តុំបញ្ចូលគ្នានូវស្ថានភាពនានាដោយចៃដន្យ និងគួរឱ្យអស់សំណើច ដូច្នេះផ្តល់នូវពិព័រណ៍មួយ ដ៏រស់រវើកនៃគំនូរព្រាង (រឿងបែបកំប្លែង) ដែលការកំប្លែងលេងសើចនិងកំណាព្យកាបឃ្លោង រួមបញ្ចូលគ្នាយ៉ាងល្អឥតខ្ចោះ។ នៅក្នុងបេះដូងនៃស្នាដៃនានារបស់គាត់ លោកស្រី Marie Losier បង្ហាញការស្រមើលស្រមៃដ៏រីករាយស្រស់បំព្រង និងរំភើបរំជើបរំជួល។ ស្នាដៃទាំងនេះ បង្ហាញឱ្យឃើញ ពីបញ្ហាប្រឈមសំខាន់ៗជាច្រើន ដូចជាសមភាពរវាងស្ត្រី និងបុរស និងយេនឌ័រ ប៉ុន្តែជាងនេះទៅទៀត លោកស្រីលើកពីជីវិតទូទៅដោយដាក់មនុស្សជាតិ នៅចំបេះដូងនៃសំណេរសិល្បៈរបស់គាត់ តាំងពីកុមារភាព ដល់វ័យជំទង់ រហូតដល់ចុងបញ្ចប់នៃជីវិត។ ការតាំងពិព័រណ៍នេះ គឺជាការអញ្ជើញឱ្យចូលរួមក្នុងពិធីបុណ្យ និងទទួលយកបទពិសោធន៍ពិធីរីករាយ។

លោកស្រីបានចាប់យកមនុស្សតាមរយៈរូបភាពបញ្ឈរខ្មៅដោយបង្កើតជាខ្សែនៃ១៣ ទំនាក់ទំនងស្និទ្ធស្នាលរវាងតារាម៉ូដែល និងសិល្បករដែលចាប់ដៃរួបរួមគ្នា តាមរយៈគំនូររបស់គាត់ (ប្រភេទគំនូរប្រេង)។

គឺជាការសន្ទនាឥតឈប់ឈរដែលត្រូវបានករកើតឡើងតាមរយៈភាសារបស់វាដែលមានខ្សែគំនូសខ្មៅច្បាស់ៗនិងជិតធូន់ ជាស្នាដៃមួយនៅលើខ្សែរបន្ទាត់ ដែលរូបភាពគឺជាចំណុចកណ្តាល។រូបភាពទាំងនេះកើនឡើងច្រើននិងប្រឈមដាក់គ្នានៅក្នុងឆាកចំណុចលម្អិតទាំងអស់គឺសំខាន់ចាំបាច់គំនូរតន្ត្រីសំឡេង ហ្វីល និងការប្រើប្រាស់ ការផ្គុំសម្ភារៈផ្សេងៗរបស់វារួមចំណែកផ្តល់អារម្មណ៍រូបភាពនៃស្នាដៃ។ លោកស្រី Marie Losier រៀបរាប់ពីការជួបជាមួយរឿងជីវិត រឿងនិទានដែលគួរដឹង រឿងទាំងនេះត្រូវបានសរសេរជាសាច់រឿង និងលេចចេញជារូបរាងមក តាមរយៈទម្រង់នានាដែលតភ្ជាប់ជាមួយគ្នា បែបកំណាព្យកាបឃ្លោង ដើម្បីបង្កើតជាសំណេររូបភាពឯកវចនៈមួយ ជាក់លាក់សម្រាប់លោកស្រី Marie Losier ។

ស្នាដៃរបស់លោកស្រីមានលក្ខណៈជាសាកល និងមនុស្សជាតិដើរតួរឆ្លុះបញ្ចាំងពីគម្លាត និងការកំប្លែងលេងសើច ដោយបានទាញយកគំនិតពីវប្បធម៌នានា ពីភាពខុសគ្នា ពីប្រវត្តិសាស្រ្តនៃវិស័យភាពយន្ត ពីកំណាព្យ និងពីសិល្បៈ នៅក្នុងលក្ខណៈពហុជំនាញ និងចម្រុះភាពដ៏ទូលំទូលាយបំផុតរបស់សិល្បៈ ប៉ុន្តែសំខាន់ជាងទាំងអស់ ពីមនុស្សជាតិ។

ឥទ្ធិពលដ៏ធំធេញ ជាប្រភពគំនិត របស់លោកស្រី គឺធំមហាសាល ឥទ្ធិពលទាំងនេះ សន្ទឹងពីវប្បធម៌ដែលខុសប្លែកពីវប្បធម៌លិចឆ្ពោក្លាយជាវប្បធម៌ដ៏ពេញនិយមនិងនៅក្រៅអឺរ៉ុប ។ លើសពីព្រំដែនសិក្សា លោកស្រី Marie Losier ធ្វើដំណើរបញ្រ្ចាសទិស ក្នុងប្រវត្តិសាស្រ្តនៃវិស័យភាពយន្ត និងសិល្បៈក្នុងពេលជាមួយគ្នាជាមួយចលនាសិល្បៈ PoP, Dada, Fluxus លោកស្រីចូលចិត្តរីករាយជាមួយឯកសារយោងទាំងនេះ ជាពិសេសជាមួយស្រ្តីដែលមានគំនិតអស្ចារ្យដូចជា៖ Maya Deren, Chantal Akerman, Barbara Stanwick, Patti Smith, Maria Callas, Blondie, Nadia Comaneci នេះគ្រាន់តែលើកឈ្មោះខ្លះៗ និង/ឬ Jonas Mékas, Bob Dylan, Lou Reed, Jack Smith, Buster Keaton, Todd Browning,The Residents …...

នៅប្រទេសកម្ពុជា លោកស្រី Marie Losier បានជ្រមុជខ្លួនយ៉ាងជ្រៅ ចូលទៅក្នុងជីវិតក្នុងស្រុក ស្វែងយល់ពីភាពសម្បូរបែបនៃទីផ្សារ ខ្សែសូត្រពណ៌លឿង គំនូរព្រះបរមរាជវាំង ដែលតំណាងឱ្យសត្វពាក់កណ្ដាលមនុស្ស ពាក់កណ្ដាលអទិទេព ពាក់កណ្ដាលស្ត្រី ដងវិថីដ៏អ៊ូអរនៃទីក្រុងភ្នំពេញ ក៏ដូចជាតន្ត្រីរបាំអប្សរា រឿងនិទាននានា និងទេវកថានៃរូបភាពកម្ពុជា។

នៅក្នុងចង្វាក់ដែលទន់ភ្លន់ និងស្រទន់ លោកស្រីចាប់យកការលាយបញ្ចូលយ៉ាងស៊ីសង្វាក់នៃពណ៌វត្ថុនានានិងផ្ទៃមុខនៅក្នុងស្ថាបត្យកម្មដែលផ្ទុយគ្នានេះ។ ភាពសម្បូរបែបនៃបេតិកភណ្ឌ និងវប្បធម៌របស់ប្រទេសកម្ពុជាត្រូវបានផ្សារភ្ជាប់យ៉ាងស្និទ្ធស្នាលទៅក្នុងដំណើរការច្នៃប្រឌិតរបស់លោកស្រី។

រូបភាពទាំងនេះនឹងបន្សល់ទុកនូវដានមួយដែលមិនអាចលុបបាន នៅលើការងារឯករចនៈដ៏ស្មោះស្ម័គ្រ និងច្នៃប្រឌិតរបស់លោកស្រី Marie Losier ដែលសន្យាថានឹងដាក់ឱ្យចំគោលដៅ! យើងសូមអរគុណលោកស្រី ដែលបានដាក់វ៉ាលីរបស់អ្នកនៅក្នុងប្រទេសកម្ពុជាដូច្នេះផ្ដល់ជូននូវដំណើរកម្សាន្តបែបសិល្បៈដ៏ពិសេសមួយ នៅវិទ្យាស្ថានបារាំង!

លោក វ៉ាំឡង់តាំង រ៉ូឌ្រីហ្គេស



Marie Losier, *Manuelle Labor,* 2007, 16 mm
© Galerie Anne Barrault

## សម្រង់របស់លោកស្រី Marie Losier

« សិល្បៈនយោបាយ គឺជាគំនិតមួយទើបកើតមានថ្មីៗនេះទេ។ខ្ញុំមិនដឹងទាល់តែសោះថាឆ្លើយយ៉ាងដូចម្តេចទេ ខ្ញុំគិតអំពីវាពេលធ្វើការ។ ឧទាហរណ៍ ពេលខ្ញុំផលិតរឿង *"Cassandro, the Exotico!"* ខ្ញុំមិនផលិតខ្សែភាពយន្តអំពីមនុស្សស្រលាញ់ភេទដូចគ្នាទេ ប៉ុន្តែភាពយន្តរបស់ខ្ញុំមានលក្ខណៈនយោបាយព្រោះវា ពិពណ៌នាបង្ហាញពីសិល្បៈករទាំងឡាយ និងអ្នកដែលនៅក្រៅស្តង់ដាសង្គមអ្នកសេរីនិយមពិតៗកវីដែលមិនដើរតាមច្បាប់សង្គម ហើយពិបាកនឹងចាត់ថ្នាក់។ មនុស្សដែលទទួលយកហានិភ័យ ដកពិសោធន៍ និងបញ្ចេញមតិដោយសេរី។ មិនមានការវិនិច្ឆ័យអ្វីទេ នៅក្នុងខ្សែភាពយន្តរបស់ខ្ញុំ គ្រាន់តែមានស្នេហា។ សិល្បករទាំងនេះគឺជាវីរបុរសរបស់ខ្ញុំ។ »

Ed. Semiose, collection *Pleased to meet you*, Paris 2021

«ឥឡូវនេះ តួអង្គសម្តែងទាំងអស់ មិត្តភ័ក្តិរបស់ខ្ញុំ ខ្ញុំស្លៀកពាក់ឲ្យពួកគេច្រើនជាងមុន ខ្ញុំយកវត្ថុសិល្បៈមកបំពាក់ក្នុងក្របខណ្ឌនៃការថត។ ពួកគេនឹងក្លាយជាមានលក្ខណៈប្រឌិតកាន់តែច្រើន ដោយសារខ្ញុំកាន់តែមានភាពងាយស្រួលជាមួយនឹងសម្ភារៈនិយម និងសូម្បីតែជាមួយពណ៌ ដែលជាដំណើរការថ្មីសម្រាប់ខ្ញុំ។ប៉ុន្តែអ្វីដែលសំខាន់បំផុតគឺមនុស្ស។ »

Ed. Semiose, collection *Pleased to meet you*, Paris 2021



Marie Losier, *Cassandro the Exotico !*, 2018, Paris
© Galerie Anne Barrault

# វាចារបស់សិល្បការិនី

ស្នាដៃទាំងអស់នៅក្នុងការតាំងពិព័រណ៍នេះ មានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយវិស័យភាពយន្តការលេងសើចកំប្លែងលាយហឹង្សារាងបំផ្លើសដោយមានចេតនា (slapstick) វេទមន្តនៃខ្សែភាពយន្តនិងការបង្កើតខ្សែភាពយន្តផ្ទាល់របស់ខ្ញុំហ្វីលកុនកាមេរ៉ា ក៏ដូចជាមនុស្ស និងសត្វនានា ដែលខ្ញុំចូលចិត្តថត និងធ្វើឱ្យទៅជាអមតៈ។ សម្រាប់ខ្ញុំ ពួកគេគឺជាតារាផ្ទាល់របស់ខ្ញុំ ។

ក្នុងចំណោមការច្នៃប្រឌិតផ្សេងៗគ្នាដែលកំពុងដាក់ពិព័រណ៍នេះ ខ្សែភាពយន្តជាច្រើននឹងត្រូវបានបង្ហាញ។ ដូច្នេះហើយស្នាដៃជាច្រើនត្រូវបានផលិតឡើង ដើម្បីបង្ហាញខ្សែភាពយន្តទាំងនេះនៅក្នុងវិចិត្រសាលតាមរយៈការដំឡើងនានា។

សេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះវិស័យភាពយន្តគឺបែបនេះ សម្រាប់ខ្ញុំ ការតាំងពិព័រណ៍ តំណាងឱ្យឱកាសមួយ ដើម្បីជំរុញការចាប់អារម្មណ៍ស្រលាញ់ដូចគ្នានេះចំពោះអ្នកដទៃទៀត។ គោលបំណងចម្បងរបស់ខ្ញុំតាមរយៈការតាំងពិព័រណ៍នេះ គឺដើម្បីបង្កើត ចំពោះអ្នកទស្សនា ចំណងចំណូលចិត្តនៃការទៅមើលកុន នៃភាពសប្បាយរីករាយ ហើយដោយមិនបានដឹងខ្លួន ជារឿយៗមានភាពរំភើបរំជើបរំជួលផងដែរ។ រោងកុន វិចិត្រសាល រោងមហោស្រព គឺជាកន្លែងវេទមន្តអស្ចារ្យ ដែលយើងបំភ្លេចខ្លួនយើង ដើម្បីសុបិនស្រមើស្រម៉ៃ និងជាកន្លែងដែលអារម្មណ៍របស់យើងត្រូវបានលេចឡើងយ៉ាងពេញលេញ រវាងសំណើច ទឹកភ្នែក កំហឹង និងភាពរីករាយសប្បាយ។ នេះជាការបង្កើតឡើង ដើម្បីអាចរីករាយដកពិសោធន៍យ៉ាងពេញលេញ និងបន្តសុបិនទៀត។



© Institut français du Cambodge

## ជីវប្រវត្តិរបស់លោកស្រី Marie Losier

លោកស្រី Marie Losier កើតនៅប្រទេសបារាំង ក្នុងឆ្នាំ១៩៧២ គឺជាអ្នកដឹកនាំរឿង និងជាសិល្បការិនីផ្នែកសិល្បៈប្លាស្ទិចម្នាក់។ លោកស្រីបានសិក្សាអក្សរសាស្ត្រនៅសាកលវិទ្យាល័យ Nanterre (DEA, សញ្ញាប័ត្រអនុបណ្ឌិតផ្នែកអក្សរសិល្ប៍និងកំណាព្យអាមេរិក) និងវិចិត្រសិល្បៈនៅទីក្រុងញូវយ៉ក (MFA/Hunter College)។ ជាទីក្រុងដែលលោកស្រីបង្កើនការស្រលាញ់ពេញចិត្តចំពោះវិស័យភាពយន្ត។ នៅទីនោះលោកស្រីបានបង្កើតស្នាដៃជាភាពយន្តពិពណ៌នាបង្ហាញជាច្រើន បែបឈានមុខគេ ស្និទ្ធស្នាល កំណាព្យកាបឃ្លោង និងកំប្លែងលេងសើចរបស់អ្នកផលិតភាពយន្តតន្ត្រីករនិងអ្នកតែងនិពន្ធដូចជា Alan Vega, បងប្អូន Kuchar, Guy Maddin, Richard Foreman, Tony Conrad និង Jackie Raynal et Felix Kubin.។

ខ្សែភាពយន្តរបស់លោកស្រី ត្រូវបានចាក់បញ្ចាំងជាញឹកញាប់ នៅក្នុងពិធីមហោស្រពល្បីៗ (ក្រុង Cannes, ទីក្រុងប៊ែរឡាំង , ទីក្រុងRotterdam, IDFA, Tribeca / ញូយ៉ក, CPH:-DOX, Bafici / អាហ្សង់ទីន, Cinéma du Réel, Torino, etc.) ប៉ុន្តែក៏មាននៅក្នុងសារមន្ទីរនានាដូចជានៅវិចិត្រសាល Tate Modern (ទីក្រុងឡុងដ៍) នៅសារមន្ទីរ MoMA (ទីក្រុងញូយ៉ក), មជ្ឈមណ្ឌល Pompidou, ឬសូម្បីតែនៅបណ្ណាល័យភាពយន្តបារាំង(ទីក្រុងប៉ារីស) និងសារមន្ទីរ Whitney (ទីក្រុងញូយ៉ក) ។

ខ្សែភាពយន្តខ្នាតវែងដំបូងរបស់លោកស្រីគឺ *"The Ballad of Genesis and Lady Jaye"* បានពិពណ៌នាបង្ហាញយ៉ាងយកចិត្តទុកដាក់ ពីសិល្បករសម្តែង Genesis Breyer P-Orridge (ក្រុម Throbbing Gristle and Psychic TV) និងដៃគូរបស់គាត់ Lady Jaye ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងជាលើកដំបូងនៅមហោស្រពភាពយន្តទីក្រុងប៊ែរឡាំង ក្នុងខែកុម្ភៈឆ្នាំ ២០១១ ដោយបានឈ្នះពានរង្វាន់ Teddy award និងពានរង្វាន់ Caligari ។

ខ្សែភាពយន្តនេះក៏បានឈ្នះពានរង្វាន់ធំ (Grand Prix) នៅ Indielisboa, រង្វាន់ Louis Marcorelles និងរង្វាន់បណ្ណាល័យ (Cinéma du Réel)។ ខ្សែភាពយន្តនេះត្រូវបានចាក់បញ្ចាំងនៅប្រទេសបារាំង កាណាដា ម៉ិកស៊ិក សហរដ្ឋអាមេរិក និងប្រទេសអាល្លឺម៉ង់។

ក្នុងឆ្នាំ ២០១៣/១៤ លោកស្រី Marie Losier បានឈ្នះពានរង្វាន់ DAAD Residency Award ដ៏ល្បីល្បាញនៅទីក្រុងប៊ែរឡាំង និងពានរង្វាន់ Guggenheim Award ដើម្បីធ្វើការលើខ្សែភាពយន្តថ្មីរបស់លោកស្រី *" Cassandro the Exotico! "* ដែលជាភាពយន្តពិពណ៌នាបង្ហាញពីអ្នកចំបាប់ជនជាតិម៉ិកស៊ិកដ៏ល្បីល្បាញ Saul Almendariz ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងជាលើកដំបូងនៅលពិភពលោក នៅឯមហោស្រពភាពយន្តទីក្រុង Cannes (ACID) ក្នុងខែឧសភា ឆ្នាំ២០១៨។ ភាពយន្តនេះត្រូវបានចាក់បញ្ចាំងនៅតាមរោងកុន នៅប្រទេសបារាំងក្នុងខែធ្នូ ឆ្នាំ២០១៨ ហើយការចាក់បញ្ចាំងនៅអាមេរិកត្រូវបានគ្រោងធ្វើឡើង នៅខែកក្កដាឆ្នាំ២០១៩(ជាមួយនឹងការបញ្ចាំងលើកដំបូងនៅរោងកុន Metrograph NYC) ។

លោកស្រី Marie Losier ក៏មានការតាំងពិព័រណ៍ផ្ទាល់ខ្លួនមួយ នៅឯវិចិត្រសាលនៃសិល្បៈសហសម័យ BBB ក្នុងទីក្រុង Toulouse ក្នុងពិធីមហោស្រព Printemps de Septembre ឆ្នាំ២០១៨ ។

ហើយលោក Eric Mangion បានធ្វើជាស្នងការនៃពិព័រណ៍មួយ ជាមួយលោកស្រី Marie Losier និង លោកស្រី Pauline Curnier-Jardin នៅមូលនិធិ Ricard ក្នុងឆ្នាំ២០១៩ ។

នៅឆ្នាំដដែលនេះដែរព្រឹត្តិការណ៍មើលថតក្រោយឡើងវិញចំនួនពីរ ក្នុងពិធីមហោស្រពសរទរដូវនៅ Jeu de Paume ក្នុងទីក្រុងប៉ារីស និងនៅបណ្ណាល័យភាពយន្តនៃទីក្រុងអាតែន (Cinémathèque d'Athènes) បានសរសើរស្នាដៃរបស់លោកស្រី ហើយនៅឆ្នាំ២០២២ គឺនៅ បណ្ណាល័យភាពយន្ត (Cinématek) នៃទីក្រុងប្រ៊ុចសែល។

នៅឆ្នាំ២០១៩លោកស្រីបានបង្ហាញខ្សែភាពយន្តថ្មីមួយដែលជាខ្សែភាពយន្តខ្នាតមធ្យម ពហុទម្រង់ ជាខ្សែភាពយន្តការដំឡើងឆាក និងការសម្តែងរបស់អ្នកតែងនិពន្ធ និងតន្ត្រីករជនជាតិអាឡឺម៉ង់ Felix Kubin (*"Felix in Wonderland!"* ចាក់បញ្ចាំងលើកដំបូងនៅមហោស្រព Locarno) ។

នៅខែមករាឆ្នាំ ២០២០ ការតាំងពិព័រណ៍ផ្ទាល់ខ្លួនមួយទៀតសម្រាប់លោកស្រី ធ្វើឡើងនៅវិចិត្រសាល Anne Barrault ។ បច្ចុប្បន្ននេះ លោកស្រី Marie Losier កំពុងបង្ហាញការតាំងពិព័រណ៍ថ្មី *"Excesso Chamalo"* នៅវិចិត្រសាល Anne Barrault ។

ការតាំងពិព័រណ៍ផ្ទាល់ខ្លួនចំនួនបីផ្សេងទៀតកំពុងត្រៀមរៀបចំ ៖ នៅឆ្នាំ ២០២៤ នៅ Creux de L'enfer à Thiers ក្នុងឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសិល្បៈ Transpalette និង នៅ FRAC Dunkerque ។

បច្ចុប្បន្ននេះ លោកស្រី Marie Losier កំពុងធ្វើការលើខ្សែភាពយន្តចំនួន៣ គឺភាពយន្តបែបពិពណ៌នាបង្ហាញពីតារាចម្រៀង/សម្តែងស្រី Peaches – *"Peaches Goes Bananas!"* -ផលិតដោយ Tamara Films និង Michigan Films ភាពយន្តបែបពិពណ៌នាបង្ហាញនៃក្រុម The Residents - *"The Residents, Behind The Mask"* - ផលិតដោយ Barberousse films និងរឿងប្រឌិតដំបូង រឿងកំប្លែងបែបតន្ត្រី - *"Sugar Bomb"* - និពន្ធរួមគ្នាដោយ Antoine Barrault និងសហការផលិតដោយ Tamara Film និង Kidam ។



Marie Losier, *If you like it don’t watch it*, 2022,technique mixte
© Galerie Anne Barrault

## “ បើអ្នកចូលចិត្តវា កុំមើលវា ”

ភ្នែកទាំងនេះគឺជាការកោះហៅឱ្យចូលក្នុងល្បែងដែលត្រូវបានបង្កើតឡើងនៅជុំវិញការសម្លឹងមើលរវាងអ្នកនៅពីមុខវាំងននអ្នកនៅពីក្រោយនិងអ្នកដែលត្រូវបានគេសម្លឹងមើល។លោកស្រី Marie Losier ទៅហួសពីដែនធម្មជាតិនៃផ្ទៃមុខនេះដែលភ្នែករបស់ពួកគេ ក្លាយជានិមិត្តសញ្ញា នៃកែវភ្នែករបស់កាមេរ៉ាមួយដែលត្រៀមរួចជាស្រេចដើម្បីបើកផ្លូវទៅកាន់ទិដ្ឋភាពឈុតឆាកថ្មី។ មុខហាក់ដូចជាបើកចំហ បិទ ឬសូម្បីតែលាក់មុខ។ កាយវិការនេះផ្តល់នូវភាពស្វាហាប់ដល់ស្នាដៃសិល្បៈ ដោយផ្តល់នូវបុគ្គលិកលក្ខណៈពិតប្រាកដមួយ។ការលេងពណ៌ស្រាលៗក៏ស្វែងរកកន្លែងរបស់ខ្លួនក្នុងការរចនាបង្កើតទេសភាពឈុតឆាក ពង្រឹងភាពច្បាស់លាស់នៃវាំងនន និងសង្កត់ថាមពលនៃក្រសែភ្នែកទៅលើទស្សនិកជន។លក្ខណៈរបស់មនុស្សដូចជាស្នាមជ្រីវជ្រួញ លក្ខណៈគំនូសខ្មៅ និងផ្នត់ៗ ធ្វើឱ្យវាំងនននេះមានជីវិតជីវ៉ា។បន្ថែមពីនេះទៀតមានលក្ខណៈមើលឃើញតាមភ្នែក និងអារម្មណ៍ ដោយបង្កើតស្នាដៃមួយ ដែលធាតុនីមួយៗចូលរួមចំណែកក្នុងការផ្តល់លក្ខណៈមនុស្សដល់វាំងននក្រោមការគូសវាសរបស់អ្នកដឹកនាំរឿង ដែលនៅពីក្រោយកាមេរ៉ារបស់គាត់។

តាមរយៈការភ្ជាប់យ៉ាងប៉ិនប្រសប់នូវសម្ភារៈសិល្បៈផ្សេងៗគ្នា សិល្បការិនីបង្កើតស្នាដៃមួយ នៅព្រំដែនរវាងល្ខោន និងកុន។ គឺតាមរបៀបឆ្លាតវៃនេះហើយ ដែលលោកស្រី Marie Losier ប្រើធាតុផ្សេងៗគ្នានេះ ដើម្បីផ្តល់ជីវិតដល់ស្នាដៃសិល្បៈរបស់លោកស្រី។ចំណុចលម្អិតនីមួយៗបានក្លាយជាការប្រៀបធៀបមួយតាមរយៈរូបភាពមើលឃើញ បញ្ជាក់បង្ហាញពីភាពសម្បូរបែបនិងភាពស្មុគស្មាញនៃបទពិសោធន៍ភាពយន្ត។នេះហើយជាធាតុចូលនៃការនិទានរឿង វាសន្យាផ្តល់នូវការភ្ញាក់ផ្អើលមួយដែលអាចត្រូវបានលាក់ទុកនៅពីក្រោយផ្នត់របស់វាដោយបន្ថែមភាពអាថ៌កំបាំងមួយ។



Marie Losier, *Eat My Makeup !*, 2019, Paris
© Galerie Anne Barrault

## *« Eat my makeup ! »*

តាមរយៈស្នាដៃសិល្បៈនេះ លោកស្រី Marie Losier ផ្ដល់ជូននូវទំនាក់ទំនងរវាងការសើច និងភាពរីករាយក្នុងការញ៉ាំ។ លោកស្រីរួមបញ្ចូលគ្នា នូវបង្អែមនំផ្អែម និងការបញ្ចាំងភាពយន្ត។ នំខេកនេះ ទទួលបានមុខងារថ្មីមួយ ពីព្រោះវាដើរតួ ជាអេក្រង់រោងកុន ដែលនៅលើនោះខ្សែភាពយន្ត *“Eat my makeup !”* ត្រូវបានចាក់បញ្ចាំង ដោយបង្ហាញនៅលើឆាក ពីការប្រយុទ្ធគ្នាដ៏ឆ្កួតលីលារបស់នំខេកដាក់ក្រែម នៅលើដំបូលនៃទីក្រុងញូវយ៉កជាទីក្រុងដែលលោកស្រីMarieLosierផលិតខ្សែភាពយន្តទាំងអស់របស់លោកស្រី។ ភាពយន្តនេះធ្វើតាមគោលគំនិតនៃកុនបែបពិសោធន៍ (cinéma underground)៖ វាត្រូវបានផលិតដោយគ្មានថវិកា ជាមួយមិត្តភក្តិរបស់លោកស្រី Marie Losier ។ យើងកត់សម្គាល់វត្តមានរបស់អ្នកដឹកនាំរឿងដ៏ប៉ិនប្រសប់លោកGeorgeKucharដែលស្លៀករ៉ូបនិងខោខ្លីដែលធ្លាក់ចុះដោយសង្កត់លើប្រធានបទនៃការកំប្លែងលេងសើចនិងការសើចសប្បាយ។លោកស្រីMarie Losier លើកទឹកចិត្តដល់ការចង់ដឹងចង់ឃើញរបស់មនុស្សម្នាក់ៗ ដោយជំរុញឱ្យមានបំណងប្រាថ្នាចង់លិទ្ធក្រែមពីនំខេកនេះ ដោយធ្វើឱ្យពួកគេស្រក់ទឹកមាត់។

នេះជាការអញ្ជើញឱ្យចូលលេង និងទទួលយកការភ្ញាក់ផ្អើលដោយជ្រើសរើសនំពិតប្រាកដមួយ ដែលនឹងអាចត្រូវលេបត្របាក់ដោយអ្នកគ្រប់គ្នាក្នុងអំឡុងពេលបើកសម្ពោធការតាំងពិព័រណ៍របស់លោកស្រី។ ដោយធ្វើបៀបនេះ អ្នកគ្រប់គ្នាមានឱកាសចាកចេញពីការតាំងពិព័រណ៍ ជាមួយនឹងបំណែកមួយនៃស្នាដៃ នៅក្នុងពោះរបស់ពួកគេ។ ការញ៉ាំនំនេះ ក៏មានន័យថាភ្លក់នូវខ្សែភាពយន្ត ដែលគ្របដណ្ដប់លើផ្ទៃនៃនំនេះផងដែរ។ ប៉ុន្មានថ្ងៃបន្ទាប់ពីការបើកសម្ពោធ ទស្សនិកជននឹងអាចឃើញការផលិតនំនេះឡើងវិញដែលលើកនេះនឹងមានលក្ខណៈសិប្បនិម្មិត។ តាមរយៈស្នាដៃនេះ លោកស្រី Marie Losier បំបែកធម្មជាតិនៃវិស័យភាពយន្តបុរាណ និងវិស័យនំដោយលេង រវាងការពិត សិល្បៈសម្ដែង និងភាពមិនម៉ត់ចត់ច្បាស់លាស់។



Marie Losier, *Eat My Makeup !*, 2015, 16mm
© Galerie Anne Barrault



Marie Losier, *ធម្មជាតិ*, ២០២២, ១៦មម,
© រូបថតពីវិចិត្រសាល Anne Barrault



Marie Losier, *Bodhi in my Body*, គំនូរព្រៀង, ២០២៤
© Marie Losier

## « *Bodhi in my Body* »

ដើមឈើនេះឈរត្រង់យ៉ាងអស្ចារ្យមើលឃើញមានដើងហើយមែកនិងឫសរបស់វា មានជីវិតជីវ៉ា រមួលបត់កោងចូលគ្នា និងបត់បែន ហាក់បីដូចជាផ្តល់ឱ្យអ្នកទស្សនានូវអារម្មណ៍នៃការប្រឈមមុខនឹងដើមឈើដែលរំកិល និងប្រើប្រាស់ដើងរបស់វាយ៉ាងពេញទំហឹង ដូច្នេះប្រែក្លាយឫសទៅជាដើងពិតៗ។ដោយសារចំណាប់អារម្មណ៍នៃចលនានេះអ្នកទស្សនាប្រឈមមុខនឹងដើមឈើមួយ ដែលដឹកនាំពួកគេ និងរៀបរាប់រឿងរ៉ាវមួយ ដើម្បីអមដំណើរ ខ្សែភាពយន្តរឿង ធម្មជាតិ ដែលត្រូវបញ្ចាំងនៅក្នុងកន្លែងពិសេសមួយចំនៅកណ្តាលដើមឈើ។ ដូច្នេះហើយ លោកស្រី Marie Losier បង្កើតដើមឈើចម្លែកមួយ ដែលមានជីវិតដូចជាមនុស្ស។ រុក្ខជាតិនៃទីក្រុងភ្នំពេញ និងប្រទេសកម្ពុជា គឺជាផ្លែផ្កានៃការបំផុសគំនិតរបស់លោកស្រី។ តាមពិតទៅ ដើមឈើដែលមើលឃើញជារៀងរាល់ថ្ងៃ ហាក់បីដូចជាមានវេទមន្តអស្ចារ្យ ដោយភាពធំធេងរបស់វា ភាពបត់បែនដ៏ស្រស់បំព្រង និងភាពអស្ចារ្យមហាសាលសម្រាប់សិល្បករ។ ដើមឈើនេះក្លាយជាវត្ថុយោង និងជាដៃគូ នៃខ្សែភាពយន្តរឿង ធម្មជាតិ និងពង្រឹងវត្តមាននៃប្រធានបទកុន។

ធម្មជាតិ គឺជាខ្សែភាពយន្តមួយ ដែលផ្តើននឹងច្បាប់នៃធម្មជាតិ និងទំនាញផែនដី ជាមួយនឹងថាមពល និងការស្រមើស្រមៃ ដោយផ្អែកលើទីក្រុង Thiers ។ ទីក្រុងនេះស្ថិតនៅលើជម្រាលភ្នំ តួអង្គនានាក្នុងខ្សែភាពយន្តនេះដួល ហើយធ្លាក់រមៀលធ្វើឱ្យទស្សនិកជនសើចញញឹម។ក្នុងចំណោមតួសម្តែងក្នុងរឿងនេះយើងឃើញមានក្រុមតន្ត្រីARLT។ស្នាដៃនេះគឺជាការតុបតែងឆាកកុន និងល្ខោនពិតប្រាកដ ដែលអាចបង្កើតបរិយាកាសមួយសម្បូរបែបដោយរឿងរ៉ាងប្រវត្តិសាស្ត្រ។



Marie Losier, *Mouth Me !*, បញ្ជោកទេសចម្រុះ ឆ្នាំ២០២៤

© Institut français du Cambodge

## *« Mouth Me ! »*

បន្ទាប់ពីដំណើរទស្សនកិច្ចរបស់លោកស្រីមកកម្ពុជា និងការស្វែងយល់វប្បធម៌ខ្មែរ ដែលលោកស្រី Marie Losier បានបង្កើតស្នាដៃដ៏ពិសេសនេះ។ បង្កើតជាពិសេសសម្រាប់ការតាំងពិព័រណ៌នេះ រាំងននេះមានទម្រង់ជារាំងននៃកុនបុរាណ ប៉ុន្តែមានលក្ខណៈពិសេសប្លែកមួយ៖ រាំងននេះមានជីវិត ដោយសារភ្នែកយក្សទាំងពីរ និងមាត់ដែលអណ្តាតលៀនចេញមក។ ការបើក ដែលបង្កើតឡើងដោយមាត់ ប្រើជាផ្លូវឆ្លងកាត់ទៅកាន់ពិភពលោកមួយ ដែលវប្បធម៌ខុសគ្នាពីររួមគ្នាយ៉ាងសុខដុមរមនា។ ជាការពិតណាស់ រាំងននមានចរិតលក្ខណៈរូបវន្តដែលយកលំនាំតាមផ្ទៃមុខទាំងឡាយដែលមានវត្តមាននៅលើផ្ទាំងគំនូរ និងរូបចម្លាក់ដែលមាននៅក្នុងសារមន្ទីរនានាក្នុងទីក្រុងភ្នំពេញ ដោយទទួលឥទ្ធិពលពីនិមិត្តសញ្ញា និងរឿងព្រេងបុរាណខ្មែរ។

បន្ថែមពីលើនេះទៀត គឺឥទ្ធិពលនៃ Freak Show ដែលមនុស្សលោក ដែលមានពិការភាព ឬលក្ខណៈរាងកាយខុសធម្មតា ត្រូវបានដាក់តាំងបង្ហាញនៅតាមពិធីបុណ្យតុបតែងខ្លួន (carnaval) និងទីកន្លែងបុណ្យនានានៅពាក់កណ្តាលសតវត្សទី២០ ។ ការលាយចម្រុះវប្បធម៌នេះ គឺជាបទពិសោធន៍ដ៏អស្ចារ្យដែលអាចឱ្យលោកអ្នកចូលទៅក្នុងពិភពសិល្បៈរបស់លោកស្រី Marie Losier ។ ដោយឆ្លងកាត់មាត់នេះ សាធារណជននឹងចូលក្នុងបន្ទប់រោងកុនមួយ ដែលអ្នកដឹកនាំរឿងនឹងផ្តល់ជូននូវកម្មវិធីរបស់គាត់។

# ភាពយន្ត~កំប្លែង

លំហនេះយកលំនាំគំនិតតាមបទពិសោធន៍នៃសួនកម្សាន្ត ដូចជា Luna Park ដ៏ល្បីល្បាញ តំណាងឱ្យបេះដូងនៃការងារសិល្បៈរបស់លោកស្រី Marie Losier ។ ទាំងនេះគឺជាស្នាដៃដែលទំនាក់ទំនងដ៏រឹងមាំមួយត្រូវបានបង្កើតឡើងជាមួយតួសម្តែង ដែលគ្រោងនៃសាច់រឿង ត្រូវបានរៀបចំសរសេរឡើងបន្តិចម្តងៗក្នុងពេលថតហើយដែលការបំផុសគំនិតនៅខណៈពេលនោះរបស់សិល្បករបានដឹកនាំសាច់រឿង។ ការថតរបស់លោកស្រីគឺមានន័យដូចទៅនឹងការច្នៃប្រឌិតការគិតពិចារណ៍និងអារម្មណ៍នានា។ គាត់បង្កើតច្បាប់ផ្ទាល់ខ្លួនរបស់គាត់ក៏ដូចជាគំនិតថ្មីៗ ដោយចែករំលែកជាមួយយើងនូវអារម្មណ៍នៃភាពសប្បាយរីករាយនិងការលេងល្បែង។នៅក្នុងលំហនេះបានប្រមូលផ្តុំនូវខ្សែភាពយន្តដែលលោកស្រី Marie Losier បានជ្រើសរើសមកបង្ហាញជូនយើង ដែលអាចមើលបានតែនៅក្នុងវិចិត្រសាលនៃវិទ្យាស្ថានបារាំងកម្ពុជាប៉ុណ្ណោះ។

ថតនៅចន្លោះឆ្នាំ២០០៣ និងឆ្នាំ ២០២១ ខ្សែភាពយន្តខ្នាតខ្លីជិតកៅសិបប្រាំមួយនាទី ក្នុងទម្រង់ ១៦មម បែបសុបិន្តហួសពីការពិតនិងមានលេងសើចកំប្លែងលាយហឹង្សារាងបំផ្លើសដោយមានចេតនា (slapstick) ត្រូវបានផ្តល់ជូនពួកយើង។

ស្នាដៃភាពយន្តទាំងនេះត្រូវបានអមដោយតន្ត្រី និងសំឡេងនានា ដោយគ្មានការសន្ទនា ហើយត្រូវបានចាក់ផ្សាយជាបន្តបន្ទាប់។ សិល្បការិនីអញ្ជើញទស្សនិកជនរបស់គាត់ឱ្យអង្គុយយ៉ាងស្រួល ដូចជាបន្ទប់រោងកុន ដើម្បីមើលការច្នៃប្រឌិតរបស់គាត់ ក្នុងបរិយាកាសថ្មីមួយ។ ខ្សែភាពយន្តទាំងនេះ ឆ្លុះបញ្ចាំងពីស្មារតីច្នៃប្រឌិតរបស់លោកស្រី Marie Losier ភាពស្វាហាប់របស់គាត់ គំនិតរីករាយរបស់គាត់ ដែលពោរពេញទៅដោយមនុស្សជាតិ និងសេចក្តីរីករាយក្នុងការរស់នៅ។



Marie Losier, *Taxidermisez-moi (សូមថែរក្សាទុករាងកាយខ្ញុំឱ្យនៅក្រៀមស្អាត)* ឆ្នាំ២០២១, ១៦មម
© វិចិត្រសាល Anne Barrault

## អ្នកនឹងមានឱកាសទស្សនាភាពយន្តខ្លីដូចខាងក្រោម៖

- *"Blessings of the animals"* (ពរជ័យពីហ្វូងសត្វទាំងឡាយ), ឆ្នាំ ២០០៣, ១៦ម.ម, ៣ នាទី
- *"Taxidermisez-moi"* (សូមថែរក្សាទុករងកាយខ្ញុំឱ្យនៅក្រៀមស្អាត), ឆ្នាំ២០២១, ១៦មម, ១០ នាទី
- *"Electric Storm"* (ព្យុះអគ្គិសនី) ១០០ ឆ្នាំនៃ Theremin, ឆ្នាំ២០២១, ១៦មម, ៦ នាទី
- *"Draw me now"* (គូររូបខ្ញុំឥឡូវនេះ), ២០០៧/២០១៨, ១៦មម , ៦ នាទី
- *"Excesso Chamalo"* ឆ្នាំ ២០២២, ១៦មម, ៦ នាទី
- *"Flying Saucey"* (ឆ្នាំងហោះ), ឆ្នាំ ២០០៦, ១៦មម, ១១ នាទី
- "ធម្មជាតិ" ឆ្នាំ ២០២២, ១៦មម, ៥ នាទី
- *"Lunch Break on the xerox machine"* (សម្រាកអាហារថ្ងៃត្រង់នៅលើម៉ាស៊ីន xerox), ឆ្នាំ ២០០៦, ១៦មម, ៣ នាទី
- *"Manuelle Labor" (ការងារដោយដៃ), ឆ្នាំ២០០៧, ១៦មម, super 8,* ដោយសហការជាមួយ *Guy Maddin,* ១០ នាទី
- " បក្សីនាពេលរាត្រី " ឆ្នាំ ២០១៦, ១៦ម.ម, ២០ នាទី
- *"Papal BrokenDance", ឆ្នាំ ២០០៩, super 8 & ១៦មម,* ៦ នាទី
- *"Slap the gondola "* ឆ្នាំ ២០១០, ១៦មម, ១៥ នាទី



Marie Losier, *បក្សីនាពេលរាត្រី*, ឆ្នាំ ២០១៥, ១៦មម, ២០ នាទី, ជាមួយ Deborah Kristal, Joao Pedro Rodriguez, ផលិតដោយ Indielisboa ជាមួយ Denis Cote, Gabriel Abrantes និង Dominga Sotomaya
© វិចិត្រសាល Anne Barrault



Marie Losier និង David Legrand, *Excesso Chamalo*
ឆ្នាំ ២០២២ ថតដោយកាមេរ៉ា ១៦មម
© វិចិត្រសាល Anne Barrault

## « *Excesso Chamalo* »

ភាពយន្តខ្លីនេះមានចំណងជើងថា *“Excesso Chamalo”* ត្រូវបានផលិតឡើង ក្នុងក្របខណ្ឌនៃការតាំងពិព័រណ៌មួយ ដែលមានឈ្មោះដូចគ្នា ផ្តោតលើក្ការលាយពណ៌ ដែលស្រមើស្រមៃឡើងពីបង្អែមនំ ដែលយកទម្រង់តាម ស្ករទាញពណ៌ផ្កាឈូក និងពណ៌ស។ លោកស្រី Marie Losier និងលោក David Legrand បានបង្កើតខ្សែភាពយន្តនេះឡើង ដោយស្រមៃថា តួអង្គបីនាក់ស្លៀកពាក់សំលៀកបំពាក់ពណ៌ផ្កាឈូកភាគច្រើន ហើយដែលពណ៌ស រអិលមកតិចៗ។ តាមរយៈការលេងពណ៌នេះ លោកស្រីអាចផ្តល់នូវភាពបំភាន់នៃការលាយបញ្ចូលគ្នា រវាងតារាសម្តែង និងស្ករទាញ ដើម្បីអាចឱ្យពួកគេរួមគ្នាតែមួយ។ ដូច្នេះហើយ តួឯកដ៏មហិមា នឹងក្លាយជាការប្រៀបធៀបរបស់ស្ករគ្រាប់ ដែលយើងសង្កេតឃើញតាមរយៈជំនួយពីសក់ក្រង ដ៏គួរឱ្យចង់ញ៉ាំរបស់ Louis XIV ជាស្ករគ្រាប់ដោយបង្ហាញពីតម្រូវការយ៉ាងខ្លាំងក្នុងការលេបត្របាក់សម្រាប់អ្នកដែលនៅជុំវិញគាត់។ ភាពយន្តនេះមិនបង្ហាញការសន្ទនាណាមួយទេ ប៉ុន្តែផ្ទុយទៅវិញ វារួមបញ្ចូលបែបផែនសំឡេង និងធនធានតន្ត្រី ដែលដកស្រង់គំនិតមកពីល្ខោនអូប៉េរ៉ា ច្រៀងដោយអ្នកដឹកនាំរឿង។

ជាមួយនឹងចក្ខុវិស័យដ៏ប៊ិនប្រសប់និងប្រកបដោយភាពច្នៃប្រឌិតមួយ ពួកគេបានផ្តល់សារៈសំខាន់យ៉ាងខ្លាំងចំពោះចលនានៃតួអង្គដែលមានវត្តមាននៅក្នុងខ្សែភាពយន្តរបស់ពួកគេ។ កាយវិការដ៏ស្វាហាប់ដូចរាំដែលតួសម្តែងមានចូលរួមក្នុងបង្កើតភាពបំភាន់បញ្ឆោតចំពោះមនុស្សគ្រប់គ្នាដែលបានចូលរួមល្ខោនសម្តែង និងតន្ត្រីមួយ ដែលប្រព្រឹត្តទៅក្រោមឥទ្ធិពលនៃភាពស្រេកឃ្លានចង់ញ៉ាំដូច្នេះហើយទើបបង្កើតបានជាខ្សែភាពយន្តមួយដែលពោរពេញដោយភាពស្រមើស្រម៉ៃយរវើរវាយ និងលេងសើចកំប្លែង។

## *« Merry Go round »*

ផ្ទាំងគំនូរនេះគូរលើក្រដាសអង្ករជាមួយថ្នាំលាបប្រេង ប្រើបច្ចេកទេស monotype ។ ខ្ពស់ និងទូលំទូលាយ ផ្ទាំងគំនូរនេះគឺជាសក្ខីកម្មសិល្បៈមួយនៃការជ្រមុជចូលក្នុងជីវិតប្រចាំថ្ងៃរបស់លោកស្រី Marie Losier នៅប្រទេសកម្ពុជា។ វាតំណាងឱ្យចំនួនមនុស្សសត្វមានជីវិតជាច្រើន ដែលភាគច្រើនជាសត្វ ។ ទាំងនេះត្រូវបានដកស្រង់គំនិតមកពីអ្វីដែលលោកស្រីបានសង្កេតឃើញ ទទួលអារម្មណ៍ យល់ឃើញ និងលេបចូលក្នុងទីក្រុងភ្នំពេញជារៀងរាល់ថ្ងៃ។ សិល្បៈខ្មែររួមផ្សំឡើងដោយតំណាងនៃសត្វពាហនៈនៅក្នុងចម្លាក់នានា រឿងព្រេង ទេវៈទេពធីតា ព្រះនាង ឬសូម្បីតែសត្វបែបកាត់ ពាក់កណ្ដាលមនុស្ស ពាក់កណ្ដាលស្ត្រី ពាក់កណ្ដាលសត្វ មករស់និងមានចលនាក្រោមកណ្ដាប់ដៃសិល្បការិនីផ្នែកសិល្បៈប្លាស្ទិចរូបនេះ។



Marie Losier, *Merry Go round*, គំនូរប្រេងនៅលើក្រដាសអង្ករ
ឆ្នាំ ២០២៤ © Institut français du Cambodge

ដូច្នេះហើយ ការច្នៃប្រឌិតដែលមើលឃើញតាមចក្ខុទាំងនេះ គឺជាការបកស្រាយផ្ទាល់ខ្លួនមួយរបស់លោកស្រីMarieLosier ចំពោះភាពរំជើបរំជួល អារម្មណ៍ដ៏រស់រវើកនៃវប្បធម៌ទីក្រុងភ្នំពេញ។ គ្រប់ជ្រុងផ្លូវ រាល់រូបចម្លាក់នីមួយៗ និងគ្រប់ទេវកថារៀបរាប់រឿងមួយដែលសំបូរទៅដោយភាពចម្រុះ និងនិមិត្តតំណាង។ ផ្ទាំងគំនូរនេះ ដើរតួជាផ្ទាំងក្រណាត់ដើម្បីចាប់យក និងបង្ហាញពីឥទ្ធិពល និងការយល់ឃើញដ៏ច្រើននេះ បង្កើតជានិទានកថាជាក់ស្ដែងមើលឃើញដោយភ្នែក។ ដោយសាររូបតំណាងនានា ឈុតឆាកមួយ ពិតជាលេចចេញបង្ហាញនៅចំពោះមុខទស្សនិកជន ហាក់ដូចជារៀបរាប់ប្រាប់រឿងរ៉ាវមួយ។ស្នាដៃនេះហាក់ដូចជាផុសចេញពីអុបទិកនៃកាមេរ៉ានិងដូច្នេះហើយបង្កើតជាផ្ទាំងរឿងដ៏ធំសម្បើមមួយហើយក៏បង្កើតភាពស្របគ្នាជាមួយនឹងពិភពភាពយន្ត។តាមរយៈការរៀបរាប់បង្ហាញរឿងនៅក្នុងស្នាដៃ ដ៏គួរឱ្យចាប់អារម្មណ៍នេះ លោកអ្នកនឹងសង្កេតឃើញក្នុងស្នាដៃនេះ នូវភាពយន្តខ្នាតខ្លី *“Félix et le Hibou”* ( ឆ្នាំ២០១៩ )។



Marie Losier, *Merry Go round*, គំនូរប្រេងនៅលើក្រដាសអង្គរ ឆ្នាំ ២០២៤ © Institut français du Cambodge



Marie Losier, *Merry Go round*, គំនូរប្រេងនៅលើក្រដាសអង្គរ ឆ្នាំ២០២៤ © Institut français du Cambodge











Marie Losier, *Lunch Break on the xerox machine*, 2003, 16mm, 3 min
© វិចិត្រសាល Anne Barrault



Marie Losier, *Flying Saucey! (ផ្ទាំងហោះ)*, ២០២១,
វីដេអូ (ឆ្នាំ២០០៦), សក់ពាក់និងអាគ្រីលីកនៅលើឈើ
© វិចិត្រសាល Anne Barrault



Marie Losier, *Felix in Wonderland*, ២០១៩, ១៦មម
© វិចិត្រសាល Anne Barrault



Marie Losier, *Rire et dance ( សើចនិងរាំ )*, ២០២១, ១៦មម
© វិចិត្រសាល Anne Barrault



Marie Losier et David Legrand, *Excesso Chamalo*, ២០២២,១៦មម
© វិចិត្រសាល Anne Barrault

## ប្រអប់ខ្សែភាពយន្ត

ប្រអប់ភាពយន្តត្រូវបានបង្ហាញជាកុនតូចៗ លក្ខណៈបុគ្គល ដោយផ្តល់នូវបទពិសោធន៍ស្និទ្ធស្នាល និងផ្ទាល់ខ្លួន។ កុននេះ លើកបង្ហាញនូវទេសភាពផ្តើមកុន ឬស្គុបតូនដំបូង (បែបភ្ជាប់រូបភាពទៅនឹងតន្ត្រី) ដោយបង្កើតទំនាក់ទំនងរវាង អតីតកាលនិងបច្ចុប្បន្ននៃវិស័យភាពយន្ត។ប្រអប់នីមួយៗមាន សោភ័ណភាព និងការតុបតែងផ្ទាល់ខ្លួនរបស់វា ដែលផ្តល់ ឱ្យពួកវានូវបុគ្គលិកលក្ខណៈពិតប្រាកដមួយ។ ប្រអប់មួយ ក្នុងចំណោមនោះ តំណាងឱ្យមនុស្សពាក់សក់ពាក់ មួយទៀត គឺជាការបកស្រាយឡើងវិញពីវិហារសត្វដែលដកស្រង់គំនិតពី រឿងព្រេង ចម្លាក់ និងផ្ទាំងគំនូរនៅទីក្រុងភ្នំពេញ។ ប្រអប់ មួយទៀតបង្កើតឡើងវិញនូវរុក្ខជាតិនៃទីក្រុងដ៏តូច។ប្រអប់មួយ ចុងក្រោយត្រូវបានគេតុបតែងលម្អដោយអ្វីៗដែលសិល្បការិនី ស្រលាញ់ចូលចិត្ត មាន ពណ៌ចម្រុះ និងប្លែកភ្នែក ដែល មាននៅផ្សារអូរឫស្សី ផ្សារកណ្តាល និងផ្សារទួលទំពូង ក្នុង រាជធានីភ្នំពេញ។ ប្រអប់ទាំងនេះ តំណាងឱ្យកន្លែងផ្សេងគ្នា ចំនួនបួនដែលនៅក្នុងនោះទស្សនិកជនអាចជ្រមុជខ្លួនចូលមើល បាន។

ក្នុងចំណោមប្រអប់ទាំងនេះ មានពីរត្រូវបានបំពាក់ដោយ កញ្ចក់មើលពិសេស៖ កែវឆ្លុះ (kaléidoscope) ដែលពង្រីក និងកាត់រូបភាព និងរន្ធតូច ដែលបន្លូវទម្រង់រូបភាពទៅជា កញ្ចក់មុំធំទូលាយ ដែលមានទិដ្ឋភាពគ្របដណ្តប់ច្រើន (Fisheye)។ ការងារនេះ ត្រូវបានបង្កើតឡើងជុំវិញអុបទិក និងកាមេរ៉ា ដោយអញ្ជើញអ្នកទស្សនាម្នាក់ៗឱ្យមើលឃើញ និងបកស្រាយទិដ្ឋភាពឈុតឆាកមួយតាមទស្សនៈមើលឃើញ ផ្ទាល់ខ្លួនរបស់ពួកគេ។ ភាពយន្ត ដែលត្រូវចាក់បង្ហាញក្នុង ប្រអប់ទាំងនេះ គឺជាឈុតឆាកនានាដែលត្រូវបានថតទុក រួច (Outtakes) សម្រាប់ភាពយន្តខ្នាតវែងអស់រយៈពេលជា ច្រើនឆ្នាំ។

នៅពេលដែលឈុតឆាកនានាត្រូវបានកាត់ត កំឡុងពេល កែសម្រួល ប៉ុន្តែពេលដែលលោកស្រី Marie Losier ចូលចិត្ត ឈុតឆាកទាំងនេះ លោកស្រីប្រើប្រាស់វា នៅក្នុងប្រអប់ ខ្សែភាពយន្តទាំងនេះដើម្បីធ្វើអោយពួកគេរស់ឡើងវិញ ដូច្នេះ ផ្តល់ឱ្យពួកគេនូវជីវិតទីពីរដែលគ្មានកំណត់។



Marie Losier, *Merry Go round,* គំនូរប្រេងនៅលើក្រដាសអង្ករ, ឆ្នាំ ២០២៤
© Institut français du Cambodge

# រូបភាពបញ្ឈរ

ដាជំបូងមធ្យោបាយនៃការជួបគ្នាដំណើរការច្នៃប្រឌិតពិសេសរបស់លោកស្រីម៉ារីអាចបង្កើតជាចំណងស្និទ្ធស្នាលរវាងសិល្បការិនី និងតារាម៉ូដែល ក្រោយមកទៀតតាមការស្នើរបស់គាត់ពួកគេនាំយកនូវវត្ថុផ្ទាល់ខ្លួននិងជាទីស្រឡាញ់ក្នុងដួងចិត្តរបស់ពួកគេដោយចំណាយពេលអញ្ជើញទៅផឹកតែទុកកន្លែងសម្រាប់ភាពត្លុកកំប្លែង។ដូច្នេះហើយការបង្ហាញពីភាពស្មុគស្មាញនៃបុគ្គលិកលក្ខណៈនីមួយៗដែល គាត់គូរសម្រាប់យើង។

ដោយឯកឯងមិនបានគិតទុក លោកស្រីបានប្រើបច្ចេកទេស monotypeជាបញ្ចេកទេសដែលពង្រាយទឹកថ្នាំក្រាស់ខ្លាំងនៅលើផ្ទាំងកញ្ចក់ឬប្រភេទកញ្ចក់Plexiglasមុនពេលដាក់សន្លឹកក្រដាសអង្ករជប៉ុន។

ដំណើរការនេះត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សវាក៏ជៀសវាងការសម្លឹងមើលក្រដាសពីព្រោះវាត្រូវគ្នាទៅនឹងភាពអវិជ្ជមាន។ ដូច្នេះបច្ចេកទេសនេះគឺខិតជិតនឹងបញ្ចេកទេសហ្វីល។ហ្វីលនេះ ក៏មានវាយនភាពផ្នែកខាងក្រៅនៃខ្សែភាពយន្ត (ក្រដាសស្នាបទៅរាងគ្រាប់ៗរដុបៗ) ហើយយើងអាចបន្ថែមស្រមោល និងពន្លឺបាន។

បន្តិចម្តងៗលោកស្រីក៏ពាំនាំមកនូវភាពទាក់ទាញនៃភាពយន្តកាន់តែច្រើនឡើង។ តាមរយៈការស្លៀកពាក់ លោកស្រីបាននាំយកល្បិចសិល្បៈបញ្ឆោតមកដាក់ក្នុងក្របខណ្ឌនៃរូបបញ្ឈរដោយបង្កើតបានជាការលាយឡំដ៏ឆ្លាតវៃមួយរវាងមនុស្សនិងតួអង្គ ជាមួយនឹងទិដ្ឋភាពមិនប្រឌិត។



Marie Losier, *David Legrand*, ឆ្នាំ ២០១៩ គំនូរប្រេងនៅលើក្រដាសអង្ករ,៩៨ x ៦១ សង់ទីម៉ែត្រ / ១០៤ x ៧២ សង់ទីម៉ែត្រ (ជាមួយស៊ុម)
© រូបថត Aurélien Mole. វិចិត្រសាល Anne Barrault

## ការជ្រើសរើសដោយសេរី របស់លោកស្រី Marie Losier នៅរោងកុនវិទ្យាស្ថានបារាំង ចាប់ពីថ្ងៃទី ៩/២/២០២៤ ដល់ថ្ងៃទី ១០/៤/២០២៤

នៅក្នុងឱកាសនៃការតាំងពិព័រណ៍ "ផ្ទុះសំណើច!" លោកស្រី Marie Losier បានជ្រើសរើសខ្សែភាពយន្តចំនួន ១៣ ដែលនឹងធ្វើឱ្យលោកអ្នករីករាយសប្បាយនិងផ្ទុះសំណើចពេញមួយរដូវកាល។ ភាពយន្តខ្លីចំនួនបួនរបស់លោកស្រី Marie Losier ក៏នឹងត្រូវចាក់បញ្ចាំង នៅថ្ងៃតែមួយនៃការបើកការតាំងពិព័រណ៍ផងដែរ។

## ការជ្រើសរើសដោយសេរី៖

- « *The Ballad of Genesis and Lady Jaye* »
- « ក្រុម Leningrad ទៅអាមេរិកហើយ »
- « ភ្លើងឆាបឆេះ»
- « *Oscar* »
- « លោក Ruggles នៃទីក្រុង Red Gap »
- « អ្នកទស្សនា »
- « *Fantômas* »
- « *Cry-Baby* »
- « កីឡាដែលបុរសៗចូលចិត្ត »
- « ពពៃ »
- « ចូរយើងកុំខឹង »
- « *Les Tontons flingueurs* »
- « ថ្ងៃមួយ ឆ្នាំមួយ »

## *The Ballad of Genesis and Lady Jaye*



© IndieWire

០៩/០២/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

ដឹកនាំរឿងដោយលោកស្រី Marie Losier ភាពយន្តឯកសារនេះរៀបរាប់រឿងរ៉ាវរបស់សិល្បករ Breyer P-Orridge Genesis និងដៃគូជីវិត និងដៃគូសិល្បៈរបស់គាត់ Lady Jaye Breyer P'Orridge ។ គូស្នេហ៍មួយគូនេះ ប្រឈមនឹងដែនកំណត់នៃសិល្បៈ និងជីវវិទ្យា តាមរយៈការសម្តែងដ៏ប្រថុយប្រថាន និងមហិច្ឆតាក្នុងគោលបំណងបញ្ចូលគ្នាទៅជាបុគ្គលតែមួយ។ភាពយន្តឯកសារនេះបង្ហាញពីទង្វើពិតនៃសេចក្តីស្រឡាញ់ និងការលះបង់។

## ក្រុម *Leningrad* ទៅអាមេរិកហើយ



© IMDb

ថ្ងៃទី ១០/០២/២០២៤ - ម៉ោង២:០០រសៀល

ក្រុម Rock'n Roll របស់រុស្ស៊ី Leningrad Cowboys ក្នុងដំណាក់កាលគ្មានជោគជ័យ និងគ្មានអនាគតក្នុងពិភពតន្ត្រី សម្រេចចិត្តចាកចេញពីតំបន់ស៊ីបេរីទៅអាមេរិកក្នុងក្តីសង្ឃឹមស្វែងរកភាពល្បីល្បាញ។ ក្នុងអំឡុងពេលធ្វើដំណើរទៅកាន់គោលដៅនេះ ក្រុមនេះបានឆ្លងកាត់ទ្វីបអាមេរិក ដែលនៅទីនោះពួកគេរួមបញ្ចូលគ្នានូវក្បាច់តន្ត្រីរបស់ពួកគេ ជាមួយនឹងការស្វែងយល់សិល្បៈរបស់ពួកគេ។

## *ភ្លើងឆាបឆេះ*



© Strand Releasing

ថ្ងៃទី ១០/០២/២០២៤ - ម៉ោង៤:០០រសៀល

ខ្សែភាពយន្តបារាំង-ព័រទុយហ្គាល់ ភ្លើងឆាបឆេះ (Feu follet) ហៅផងដែរថា Will-o'-the-Wisp រៀបរាប់ពីការចងចាំរបស់តួឯក Alfredo ។ នៅពេលដែលគាត់កំពុងស្លាប់ Alfredo ចងចាំពីការជួបរបស់គាត់ជាមួយ Afonso ដែលជាគ្រូរបស់គាត់ នៅក្នុងនាយកដ្ឋានពន្លត់អគ្គីភ័យ។ដូច្នេះហើយយើងនឹងស្វែងយល់ដោយភាពរីករាយនូវជីវិតរបស់យុវជនទាំងពីរអ្នកនេះ រវាងសេចក្តីស្រឡាញ់ ចំណង់ចំណូលចិត្ត និងចលាចលនានា។

## *Oscar*




© Allociné

១៤/០២/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

Bertrand មានជីវិតដ៏ស្ងប់ស្ងាត់មានក្តីសុខមួយ។ រហូតដល់ថ្ងៃដែលបុរសដែលគាត់ទុកចិត្ត គឺ Christian បានឱ្យគាត់ច្រៀង ដើម្បីបានឡើងប្រាក់ខែរបស់គេទ្វេដង និងសុំកូនស្រីគាត់ជាគូរគាប់ដែលបុរសនេះជាគូស្នេហ៍កូនស្រីគាត់។ គេក៏សារភាពថាលួចពីគាត់ ជាច្រើនឆ្នាំមកហើយ។អ្វីៗកាន់តែស្មុគ្រស្មាញទៅនៅពេលដែលស្រីកំណាន់របស់ Christian មិនមែនជា Colette ជាកូនស្រីរបស់ Bertrandទេ ប៉ុន្តែផ្ទុយទៅវិញ Colette បែរជាមានផ្ទៃពោះជាមួយ Oscar ដែលជាអ្នកបើកបរទៅវិញ។

## *Ruggles of Red Gap*



© TimeOut

ថ្ងៃទី ១៧/០២/២០២៤ - ម៉ោង២:០០រសៀល

ខ្សែភាពយន្តនេះ រៀបរាប់ពីរឿងរបស់មេការផ្ទះ Marmaduke Rugglesដែលបន្ទាប់ពីត្រូវបានគេដាក់ក្នុងល្បែងកំឡុងពេលល្បែងបៀរ ដោយលោកម្ចាស់ Burnstead ត្រូវបង្ខំចិត្តឱ្យដើរតាមប្តីប្រពន្ធអភិជន ជនជាតិអាមេរិកមួយគូ ទៅកាន់ទីក្រុងនៃ Red Gap នៅសហរដ្ឋអាមេរិក។ ដូច្នេះ Marmaduke Ruggles រកឃើញវប្បធម៌ថ្មីមួយ ដែលផ្តល់ឱ្យគាត់នូវរសជាតិនៃសមភាពលក្ខខណ្ឌ។

## *អ្នកទស្សនា*



© CinéSérie

២១/០២/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

នៅឆ្នាំ ១១២៣ លោកម្ចាស់ (comte) Montmirail និងអ្នកតាមគាត់ដ៏ស្មោះត្រង់ម្នាក់ Jacquouille la Fripouille បានឃើញថាខ្លួនឆ្លងមកអនាគតឆ្នាំ ១៩៩២ បន្ទាប់ពីបានផឹកថ្នាំវេទមន្តមួយ ដែលផលិតដោយគ្រូវេទមន្ត Eusaebiusដែលគួរតែអាចឱ្យពួកគេកម្ចាត់នូវជោគវាសនាដ៏អាក្រក់មួយ។

## *Fantômas*



© CineComedies

២៨/០២/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

តួអង្គអាថ៌កំបាំងមួយរូប ប្រព្រឹត្តអំពើចោរកម្ម និងឧក្រិដ្ឋកម្ម ក្រោមឈ្មោះថា Fantômas ។ ស្នងការ Juve និងអ្នកកាសែត Fandor ម្នាក់ៗស៊ើបអង្កេតតាមរបៀបរបស់ពួកគេ។ពួកគេមិនជឿលើវត្តមាននៃមនុស្សអាក្រក់បែបនេះទេ។ប៉ុន្តែពួកគេស្ថិតនៅក្នុងស្ថានភាពត្រូវប្រឈមនឹង Fantômas ដែលវិធីសាស្ត្ររបស់គេរួមមានការប្រើរបាំងមុខ ដើម្បីប្រព្រឹត្តអំពើអាក្រក់របស់គេ។ ដូច្នេះ គេប្រើប្រាស់

## *Cry-Baby*



© myCanal

ថ្ងៃទី ០២/០៣/២០២៤ - ម៉ោង២:០០រសៀល

ជាក្មេងប្រុសអាក្រក់ពិតប្រាកដWadeWalkerទាក់ទាញក្មេងស្រីៗទាំងឡាយ។ ទោះបីជារូបគេ ត្រូវបានចាត់ទុកថាជាមនុស្សអត់តម្លៃសីលធម៌មកពីពិភពហាមគាត់នៃតន្ត្រីរ៉ុកដោយក្រុមអភិជនក្នុងស្រុកក៏ដោយ ក៏កញ្ញាដ៏មានទ្រព្យ និងសែនស្រស់ស្អាត Allison Vernon-Williamsធ្លាក់ក្នុងសម្រស់ទាក់ទាញរបស់បុរសវ័យក្មេងរូបនេះ ដែលបង្កជាការខឹងសម្បារពីសំណាក់មិត្តប្រុសផ្លូវការរបស់

# កីឡាដែលបុរសៗចូលចិត្ត



© IMDb

ថ្ងៃទី ០២/០៣/២០២៤ - ម៉ោង៤:០០រសៀល

Roger Willoughby បានមើលឃើញថាខ្លួនគាត់ត្រូវគេចុះឈ្មោះចូលរៀនវគ្គនេសាទ ផ្ទុយនឹងឆន្ទៈរបស់គាត់។ ថ្វីត្បិតតែជាអ្នកលក់ក្នុងហាងនេសាទ និងជាអ្នកនិពន្ធសៀវភៅដ៏ល្អមួយក្បាល លើប្រធានបទនេះក៏ដោយ ក៏ Roger មិនពេញចិត្តចំពោះកីឡានេះទាល់តែសោះឬសូម្បីតែត្រី។ដោយមិនចេះស្ទូចត្រីគាត់ព្យាយាមតាមគ្រប់មធ្យោបាយ ដើម្បីដកខ្លួនចេញ ហើយទីបំផុត គាត់ត្រូវធ្វើអ្វីៗគ្រប់យ៉ាងដើម្បីយកឈ្នះ និងស្តារមុខមាត់គាត់។

# ពពៃ



© Télé Star

១៣/០៣/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

កូនស្រីប្រធាននាយកប្រតិបត្តិដ៏អស្ចារ្យម្នាក់ Bens គឺជាមនុស្សមានសំណាងអាក្រក់ណាស់ ដែលអ្នកនាងត្រូវបានគេចាប់ចាប់ជំរិតពេលទៅវិស្សមកាលនៅប្រទេសម៉ិកស៊ិក។ដើម្បីស្វែងរកអ្នកនាងឪពុករបស់នាងបានជួលអ្នកស៊ើបអង្កេតឯកជនCampanaដែលគាត់បានសហការជាមួយនឹងជនអន្ធពាលចាក់ឬសឃ្យូរឆ្នាំម្នាក់ដោយសង្ឃឹមថាគេនឹងនាំគាត់ឱ្យបានជួបកូនស្រីរបស់គាត់ ...

## ចូរយើងកុំខឹង



©VOD Orange

២២/០៣/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

Antoine Beretto ជាអតីតក្មេងទំនើង ថ្ងៃមួយ បានជួបអតីតអ្នកសមគំនិតជាមួយពីរនាក់ សុំគាត់ជិះទូកទៅប្រទេសអ៊ីតាលីព្រមទាំងសុំខ្ចីលុយចំនួនបួនលានហ្វ្រង់ដែលជាចំនួនលុយដែលគាត់អាចយកមកវិញពី Léonard Michalon ។ ប៉ុន្តែផ្ទុយទៅវិញ LéonardMichalonបានទាក់ទាញកំហឹងរបស់"វរសេនីយ៍ឯក"ដែលជាទាហានអង់គ្លេស មេដឹកនាំក្រុមក្មេងទំនើងមួយក្រុម។ Antoine និងមិត្តរបស់គាត់ Jeff នឹងត្រូវការពារ Michalon ដើម្បីប្រមូលយកលុយមកវិញ ទោះបីមានវត្តក្មេងទំនើងក៏ដោយ។

## *Les Tontons flingueurs*



©myCanal

២៧/០៣/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

ជាម្ចាស់រោងចក្រត្រាក់ទ័រតូចមួយ លោក Fernand Naudin មានជីវិតដ៏ស្ងប់ស្ងាត់មួយនិងមិនមានរឿងរ៉ាវទេនៅពេលតេឡេក្រាមមួយ កោះហៅគាត់នៅទីក្រុងប៉ារីស។ គាត់មកដល់ទាន់ពេល ដើម្បីទាន់ដង្ហើមចុងក្រោយរបស់មិត្តកុមារភាពម្នាក់ Louis ដែលគេស្គាល់ថាជា "ជនជាតិម៉ិកស៊ិក" ដែលប្រគល់ឱ្យគាត់ នូវកិច្ចការខ្មៅមិនច្បាស់លាស់របស់គាត់ ក្នុងពេលតែមួយ ផ្តល់សិទ្ធិមើលថែកូនស្រីរបស់គាត់ Patricia ។ ហើយបញ្ហានានាក៏ចាប់ផ្តើម ...``

# ថ្ងៃមួយ ឆ្មាមួយ



© Allociné

១០/០៤/២០២៤ - ម៉ោង៦:៣០នាទីល្ងាច

ខណៈពេលដែល Robert កំពុងបង្រៀនសិស្សរបស់គាត់ឱ្យគោរពស្រលាញ់ធម្មជាតិ និងគុណសម្បត្តិមនុស្ស គ្រូមន្តអាគមនិងក្រុមរបស់គាត់ បានមកដល់ភូមិ។ ក្នុងចំណោមពួកគេ មាននារីវ័យក្មេងម្នាក់ឈ្មោះDianaនិងឆ្មាមួយពាក់វ៉ែនតា។ឆ្មានេះមានអំណោយទានធម្មជាតិក្នុងការផ្តល់ពណ៌មួយឱ្យមនុស្សនានា ដោយផ្អែកលើគុណធម៌ និងអំពើអាក្រក់របស់ពួកគេ។ បាតុភូតចម្លែកកើតឡើងច្រើន ដែលជំរុញឱ្យ Robert ធ្វើការស៊ើបអង្កេតរបស់គាត់។

# វាក្យសព្ទ

**កុនបែបដកពិសោធន៍ (*Cinéma underground*)៖** ជាកុនប្រភេទដកពិសោធន៍ចម្រុះ ដែលមានលក្ខណៈជារូបភាពពិសោធន៍ដែលស្ថិតនៅចន្លោះរវាងកុនបែបឯករាជ្យតវ៉ាទាមទារប្រភេទផ្សេងៗគ្នាដែលមានទំនាក់ទំនងជាប្រវត្តិសាស្ត្រទៅនឹងវប្បធម៌ដែលខុសប្លែកពីវប្បធម៌លិចឆ្លោ។

**រន្ធតូច (*Peephole*)៖** រន្ធបើកតូច ជាទូទៅនៅក្នុងទ្វារមួយបិទជាមួយនឹងសំណាញ់ ឬបន្ទះដែលអាចដកចេញបាន។ រន្ធនេះអាចឱ្យអ្នកមើលឃើញអ្វីដែលកំពុងកើតឡើងនៅម្ខាងទៀតនៃទ្វារ ដោយមិនត្រូវបានគេមើលឃើញ។

**កែវឆ្លុះ (*Kaleidoscope*)៖** ឧបករណ៍អុបទិកឆ្លុះបញ្ចាំងពីពន្លឺខាងក្រៅ ទៅជាពណ៌ គ្មានកំណត់។

**កម្សាន្ត ៖** អ្វីដែលអនុញ្ញាតឱ្យអ្នកមានភាពសប្បាយរីករាយដែលមានលក្ខណៈជាការលេងកម្សាន្ត។

***Scopitone* ៖** ជាឧបករណ៍ចាក់តន្ត្រីដោយស្វ័យប្រវត្តិដោយផ្អែក (Jukebox) នៃទសវត្សរ៍ទីឆ្នាំ៦០ ភ្ជាប់រូបភាពទៅនឹងតន្ត្រី។

**ឌីអូរ៉ាម៉ា (*Diorama*)៖** គំនូរបែបទេសភាពនៅលើផ្ទាំងក្រណាត់ បង្ហាញនៅក្នុងបន្ទប់ងងឹតមួយ ដើម្បីបញ្ឆោតបំភាន់ភ្នែក ដោយសារការលេងពន្លឺ ការពិត និងចលនា។

**មធ្យោបាយសម្ភារៈ៖** សំណុំសម្ភារៈទាំងអស់ប្រើប្រាស់សម្រាប់បង្កើតស្នាដៃសិល្បៈមួយ។

**ដូចសុបិន្ត៖** អ្វីដែលទាក់ទងនឹងសុបិន (ក្នុងពេលគេង ឬក្នុងស្ថានភាពភ្ញាក់) ។

**អុបទិក៖** វិទ្យាសាស្ត្រដែលមានគោលបំណងសិក្សាពន្លឺ និងចក្ខុវិស័យ។

***Outtakes*៖** ឆាកមួយ ជាឈុតមួយ ឬបទចម្រៀងមួយ ដែលត្រូវបានថតឬថតទុកសម្រាប់ភាពយន្តមួយ។កម្មវិធីឬអាល់ប៊ុមមួយប៉ុន្តែមិនត្រូវបានបញ្ចូលក្នុងកំណែឬច្បាប់ចុងក្រោយទេ។

**ការរៀបចំតុបតែងឆាក៖** សិល្បៈ និងបច្ចេកទេសនៃការរៀបចំឆាក កន្លែងល្ខោន។

***Slapstick*៖** ប្រភេទនៃការកំប្លែងលេងសើចដែលមានលាយហិង្សាលើរាងកាយរាងបំផ្លើសដោយចេតនា។

**ផ្ទាំងសាច់រឿង (*Storyboard*)៖** ការគូរគំនូរដែលបានធ្វើឡើងមុនពេលថត ដើម្បីមើលរូបភាពនៃលំដាប់ឈុតឆាកនៃភាពយន្ត។

***Fisheye* ៖** កញ្ចក់មុំធំទូលាយ ដែលមានទិដ្ឋភាពគ្របដណ្ដប់រហូតដល់ ១៨០° ជាមួយនឹងមាត្រដ្ឋានបានកាត់បន្ថយទៅគែម។

ការសោកស្តាយនឹងមកដល់...

# ព័ត៌មានមានផ្សេងៗ

ផ្ទះលេខ ២១៨ ផ្លូវ ១៨៤ – BP ៨២៧
+៨៥៥ (០)២៣ ៩៨៥ ៦១១ / ៦១២
**info@institutfrancais-cambodge.com**

## ម៉ោងធ្វើការ

**វិចិត្រសាលរបស់ វិទ្យាស្ថានបារាំងកម្ពុជាបើក៖**

→ ពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ ៖ ម៉ោង ១០ ព្រឹក - ម៉ោង ៦ ល្ងាច
→ ពីថ្ងៃសុក្រ ដល់ថ្ងៃសៅរ៍៖ ម៉ោង ១០ ព្រឹក - ម៉ោង ៥ ល្ងាច

វិទ្យាស្ថានបារាំងផ្តល់ជូននូវការទស្សនាពិព័រណ៍អមដោយអ្នកពន្យល់ណែនាំ ដោយឥតគិតថ្លៃ នៅវិទ្យាស្ថានបារាំងនៅកម្ពុជា។

## កក់ទុកជាមុនតាម៖

info@institutfrancais-cambodge.com

# ទស្សនកិច្ច និងសិក្ខាសាលា

## សម្រាប់សាធារណៈជនទូទៅ

**ការទស្សនាពិព័រណ៍អមដោយអ្នកពន្យល់ណែនាំ**
ជាភាសាបារាំង ខ្មែរ និងអង់គ្លេស
→ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ៖ ម៉ោង ៩ព្រឹក - ម៉ោង ៥ល្ងាច

## សាលារៀន និងអង្គការក្រៅរដ្ឋាភិបាល

**ទស្សនកិច្ចរៀបចំសម្រាប់គ្រូបង្រៀន**
ជាភាសាបារាំង ខ្មែរ ឬ អង់គ្លេស
→ កក់ទុកជាមុន - ឥតគិតថ្លៃ

**ទស្សកិច្ចអមដោយអ្នកសម្របសម្រួលពន្យល់ សម្រាប់ថ្នាក់រៀន**
ជាភាសាបារាំង ខ្មែរ ឬអង់គ្លេស
→ ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍៖ ម៉ោង ៩:00 ព្រឹក - ១២:00 រសៀល
ពីម៉ោង២:00 រសៀល - ដល់ម៉ោង ៥:00 រសៀល។
→ កក់ទុកជាមុន - ឥតគិតថ្លៃ

**ការបញ្ចាំងភាពយន្ត**

កម្មវិធីភាពយន្ត ដែលជាជម្រើសរបស់ Marie Losier

→ $2 ក្នុងម្នាក់

## ក្រុមសម្របសម្រួលផ្នែកវប្បធម៌រង់ចាំស្វាគមន៍លោកអ្នក នៅវិទ្យាស្ថានបារាំងនៃកម្ពុជា!

អ្នកគ្រប់គ្រងផ្នែកវប្បធម៌៖
កោ បូរិន

អ្នកគ្រប់គ្រងនិងសម្របសម្រួលផ្នែកភាពយន្ត៖
ថៃន រ៉ូជីវ៉ន

អ្នកទទួលខុសផ្នែកវប្បធម៌៖
Ruby CHUM
Chloé LAVENANT

អ្នកហាត់ការផ្នែកវប្បធម៌៖
អូន កញ្ញា


**ទំនាក់ទំនង៖**

info@institutfrancais-cambodge.com

Tel : +855 (0)23 985 611 / 612



យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ Anne Barrault, Elsa Delage, វិចិត្រសាល Anne Barrault , David Legrand, វេង ធារី, តាន់ វត្តី, Sinta Wibowo, ទិត្យ វាសនា និង Marie Losier ។